# អត្ថបទខ្លីៗអំពីការផ្ញើសារ និងភាសាសកល

| [*ខិត្តបណ្ណ/បញ្ចូលអត្ថបទខ្លីៗ*] |
|---|
| ជូនចំពោះសមាជិក Medi-Cal<br><br>អំឡុងពេលមានអាសន្ននៃសុខភាពសាធារណៈដោយសារ COVID-19 ( PHE ) អ្នកអាចរក្សាការធានារ៉ាប់រងរបស់អ្នកបានដោយមិនគិតពីការផ្លាស់ប្តូរស្ថានភាពទាំងឡាយរបស់អ្នកឡើយ។ ប៉ុន្តែ នៅពេល COVID-19 PHE បញ្ចប់ តំបន់របស់អ្នកនឹងពិនិត្យមើលថាតើអ្នកនៅតែអាចទទួលបាន Medi-Cal តម្លៃទាប ឬឥតគិតថ្លៃឬអត់។ ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកទទួលបានលិខិតពីតំបន់ ដោយស្នើសុំព័ត៌មានអំពីការធានារ៉ាប់រង Medi-Cal របស់អ្នក សូមផ្តល់ព័ត៌មានតាមការស្នើសុំ។<br><br>**ការផ្លាស់ប្តូរស្ថានភាព**<br>សូមបន្តរាយការណ៍អំពីការផ្លាស់ប្តូរនានានៅក្នុងគ្រួសាររបស់អ្នកទៅការិយាល័យក្នុងតំបន់របស់អ្នក។ សកម្មភាពនេះរួមមានការផ្លាស់ប្តូរប្រាក់ចំណូលរបស់អ្នក ស្ថានភាពពិការភាព លេខទូរសព្ទ ឬអាសយដ្ឋានផ្ញើសំបុត្រជាដើម។ អ្នកគួរតែរាយការណ៍ផងដែរ ប្រសិនបើនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកមានផ្ទៃពោះ ប្រសិនបើនរណាម្នាក់ចូលមករស់នៅជាមួយ ឬអ្វីៗផ្សេងទៀតដែលអាចនឹងប៉ះពាល់ដល់សិទ្ធិទទួលបាន Medi-Cal របស់អ្នក។ ការរាយការណ៍អំពីការផ្លាស់ប្តូរទាំងនេះអាចនឹងជួយអ្នកក្នុងការបន្តទទួលបានការធានារ៉ាប់រង Medi-Cal បន្ទាប់ពីបញ្ចប់ COVID-19 PHE។<br><br>**ការរាយការណ៍អំពីព័ត៌មានទំនាក់ទំនង**<br>វាជារឿងសំខាន់សម្រាប់តំបន់ដែលត្រូវមានព័ត៌មានទំនាក់ទំនងបច្ចុប្បន្នរបស់អ្នក។ សូមរាយការណ៍អំពីការផ្លាស់ប្តូរនានាពាក់ព័ន្ធនឹងព័ត៌មានទំនាក់ទំនងរបស់អ្នក ដើម្បីកុំឱ្យអ្នកខកខានព័ត៌មានសំខាន់ៗអំពីការធានារ៉ាប់រង Medi-Cal របស់អ្នក។ សូមរាយការណ៍អំពីព័ត៌មានទំនាក់ទំនងថ្មីៗទាំងអស់ដូចជា |

លេខទូរសព្ទ អាសយដ្ឋានអ៊ីមែល ឬអាសយដ្ឋានផ្ទះរបស់អ្នក ទៅការិយាល័យក្នុងតំបន់របស់អ្នក តាមអ៊ីនធឺណិត ឬតាមទូរសព្ទ អ៊ីមែល ទូរសារ ឬដោយផ្ទាល់។ អ្នកអាចស្វែងរកបញ្ជីនៃការិយាល័យក្នុងតំបន់តាមរយៈ http://dhcs.ca.gov/COL។ អ្នកក៏អាចធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់អ្នកតាមអ៊ីនធឺណិតតាមរយៈ CoveredCA.com ឬ BenefitsCal.org បានផងដែរ។

**ស្នើសុំព័ត៌មាន**

ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នកទទួលបានលិខិតពីតំបន់ ដោយស្នើសុំព័ត៌មានអំពីការធានារ៉ាប់រង Medi-Cal របស់អ្នក សូមផ្តល់ព័ត៌មាននោះ។ សកម្មភាពនេះនឹងជួយតំបន់ឱ្យធានាបានថា ការធានារ៉ាប់រង Medi-Cal របស់អ្នកនៅតែសកម្ម។

**មានសំណួរដែរទេ?**

ប្រសិនបើអ្នកមានសំណួរនានា ឬត្រូវការជំនួយពាក់ព័ន្ធនឹងការចូលប្រើការធានារ៉ាប់រង Medi-Cal របស់អ្នក ឬប្រសិនបើ Medi-Cal របស់អ្នកត្រូវបានផ្តាច់ សូមទាក់ទងការិយាល័យក្នុងតំបន់របស់អ្នក។ សំណួរដែលសួរញឹកញាប់ និងចម្លើយអាចរកឃើញនៅ [ទំព័រសំណួរដែលសួរញឹកញាប់]។

*[ផ្ទាំងបដាគេហទំព័រ]*

**សំខាន់៖** តើអ្នកបានចុះឈ្មោះនៅក្នុង Medi-Cal ហើយឬនៅ? តើព័ត៌មានទំនាក់ទំនងរបស់អ្នកបានផ្លាស់ប្តូរក្នុងរយៈពេលពីរឆ្នាំចុងក្រោយហើយឬនៅ? ផ្តល់ព័ត៌មានទំនាក់ទំនងថ្មីៗរបស់អ្នកដល់ការិយាល័យក្នុងតំបន់របស់អ្នក ដើម្បីឱ្យអ្នកអាចបន្តចុះឈ្មោះបាន។ ស្វែងរកការិយាល័យក្នុងតំបន់របស់អ្នក។

DEPARTMENT OF HEALTH CARE SERVICES




| [អត្ថបទគេហទំព័រសម្រាប់ទំព័រការិយាល័យក្នុងតំបន់] |
| --- |
| អំឡុងពេលមានអាសន្ននៃសុខភាពសាធារណៈដោយសារ COVID-19 ( PHE ) អត្ថប្រយោជន៍ Medi-Cal នៅតែទទួលបានការចុះឈ្មោះនៅក្នុងកម្មវិធីដដែល។ ប្រសិនបើព័ត៌មានទំនាក់ទំនងរបស់អ្នក ស្ថានភាពគ្រួសារបានផ្លាស់ប្តូរ សូមធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកនៅថ្ងៃនេះ ដោយទាក់ទងការិយាល័យក្នុងតំបន់របស់អ្នក តាមរយៈ៖ [លេខទូរសព្ទ ច្រក SAWS និងតំណតំបន់ទៅបញ្ចូល]។ សកម្មភាពនេះអាចជួយអ្នកក្នុងការរក្សាការធានារ៉ាប់រង Medi-Cal របស់អ្នក បន្ទាប់ពីបញ្ចប់ COVID-19 PHE។ |

<table>
<tr><th colspan="2">[បណ្ដាញសង្គម]</th></tr>
<tr><td>បុគ្គលិក Medi-Cal ដែលមានសិទ្ធិក្នុងតំបន់របស់អ្នកអាចទាក់ទងអ្នកក្នុងពេលឆាប់ៗ ដើម្បីធានាថាព័ត៌មានទំនាក់ទំនងរបស់អ្នកត្រឹមត្រូវ។ ប្រសិនបើបុគ្គលិកមិនបានទាក់ទងទេ សូមផ្ដល់ព័ត៌មានទំនាក់ទំនងថ្មីៗរបស់អ្នកដល់តំបន់ ដើម្បីឱ្យអ្នកអាចបន្តទទួលបានព័ត៌មានសំខាន់ៗអំពីការធានារ៉ាប់រង Medi-Cal របស់អ្នក៖ http://dhcs.ca.gov/COL។<br>[អាចបញ្ចូលព័ត៌មានទំនាក់ទំនងក្នុងតំបន់បាននៅទីនេះ]</td>
<td>


</td></tr>
<tr><td>តើអ្នកបានផ្លាស់ទីដែរទេ ?<br>អនុញ្ញាតឱ្យបុគ្គលិក Medi-Cal ដែលមានសិទ្ធិក្នុងតំបន់របស់អ្នកដឹង។ វាជារឿងសំខាន់ដែលត្រូវផ្ដល់ព័ត៌មានថ្មីៗរបស់អ្នក ដើម្បីឱ្យអ្នកបន្តទទួលបានព័ត៌មានអំពីការធានារ៉ាប់រង Medi-</td>
<td>
</td></tr>
</table>

Cal ដូចជាកញ្ចប់បន្តឡើងវិញ សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរ អត្ថប្រយោជន៍ ឬការរំលឹកសំខាន់ៗ ផ្សេងទៀត៖

http://dhcs.ca.gov/COL

[អាចបញ្ចូលព័ត៌មានទំនាក់ទំនងក្នុងតំបន់បាននៅទីនេះ]




តើអ្នកបានចាប់ផ្តើមការងារថ្មីហើយឬនៅ? អនុញ្ញាតឱ្យបុគ្គលិក Medi-Cal ដែលមានសិទ្ធិក្នុងតំបន់របស់អ្នកដឹង។ វាជារឿងសំខាន់ដែលអ្នករាយការណ៍អំពីប្រាក់ចំណូលថ្មីរបស់អ្នកទៅតំបន់ឱ្យបានឆាប់តាមដែលអាចធ្វើបាន។ អ្នកនឹងនៅតែទទួលបានការធានារ៉ាប់រង Medi-Cal របស់អ្នកដដែល អំឡុងពេលមានអាសន្ននៃសុខភាពសាធារណៈដោយសារ COVID-19៖ http://dhcs.ca.gov/COL។

តើអ្នកមានផ្ទៃពោះឬ? អនុញ្ញាតឱ្យបុគ្គលិក Medi-Cal ដែលមានសិទ្ធិក្នុងតំបន់របស់អ្នកដឹង។






<table>
<tr>
<td>វាជារឿងសំខាន់ដែលអ្នករាយការណ៍អំពីការផ្លាស់ប្តូរស្ថានភាពគ្រួសារឱ្យបានឆាប់តាមដែលអាចធ្វើបាន។ អ្នកនឹងនៅតែទទួលបានការធានារ៉ាប់រង Medi-Cal របស់អ្នកដដែល អំឡុងពេលមានអាសន្ននៃសុខភាពសាធារណៈដោយសារ COVID-19៖ http://dhcs.ca.gov/COL។</td>
<td></td>
</tr>
<tr>
<td>អ្នកត្រូវរាយការណ៍អំពីការផ្លាស់ប្តូរស្ថានភាពគ្រួសារទៅការិយាល័យក្នុងតំបន់ Medi-Cal ឱ្យបានឆាប់តាមដែលអាចធ្វើបាន។ អ្នកអាចរាយការណ៍អំពីការផ្លាស់ប្តូរដោយផ្ទាល់ តាមអ៊ីនធឺណិត ឬតាមទូរសព្ទ អ៊ីមែល ឬទូរសារ។ អ្នកនឹងនៅតែទទួលបានការធានារ៉ាប់រង Medi-Cal របស់អ្នកដដែល អំឡុងពេលមានអាសន្ននៃសុខភាពសាធារណៈដោយសារ COVID-19៖ http://dhcs.ca.gov/COL។</td>
<td>
</td>
</tr>
</table>

| *[អត្ថបទខ្លីៗអំពីស្គ្រីបនៃការហៅទូរសព្ទ]* | |
|---|---|
| អ្នកហៅទូរសព្ទដែលទទួលបានអត្ថប្រយោជន៍ | ភ្នាក់ងារ |

| | |
|---|---|
| តើខ្ញុំត្រូវរាយការណ៍អំពីការផ្លាស់ប្តូរស្ថានភាពគ្រួសារ ដើម្បីរក្សាការធានារ៉ាប់រង Medi-Cal របស់ខ្ញុំដែរទេ ? | **តំបន់/គម្រោងថែទាំដែលស្ថិតក្រោមគ្រប់គ្រង/ការឆ្លើយតបរបស់ដៃគូសហគមន៍៖** បាទ/ចាស អ្នកត្រូវបានតម្រូវឱ្យរាយការណ៍អំពីការផ្លាស់ប្តូរស្ថានភាពគ្រួសាររបស់អ្នក ដូចជា ប្រាក់ចំណូលជាដើម ប្រសិនបើមាននរណាម្នាក់មានផ្ទៃពោះ មានសមាជិកគ្រួសារថ្មី និងការផ្លាស់ប្តូរអាសយដ្ឋានរបស់អ្នកទៅការិយាល័យក្នុងតំបន់របស់អ្នក។ សកម្មភាពនេះអាចនឹងជួយធានាថា អ្នកបន្តទទួលបានការធានារ៉ាប់រង Medi-Cal របស់អ្នក បន្ទាប់ពីបញ្ចប់ភាពមានអាសន្ននៃសុខភាពសាធារណៈដោយសារ COVID-19 របស់សហព័ន្ធ៖ [បញ្ចូលព័ត៌មានទំនាក់ទំនងក្នុងតំបន់] |
| តើយើងត្រូវបានតម្រូវឱ្យបំពេញ និងប្រគល់កញ្ចប់បន្តឡើងវិញនោះមកវិញ នៅពេលយើងទទួលបានកញ្ចប់ទាំងនោះដែរទេ ? | **តំបន់/គម្រោងថែទាំដែលស្ថិតក្រោមការគ្រប់គ្រង/ការឆ្លើយតបរបស់ដៃគូសហគមន៍៖** បាទ/ចាស វាជារឿងសំខាន់ដែលអត្ថប្រយោជន៍ Medi-Cal ឆ្លើយតបទៅតំបន់ ស្នើសុំព័ត៌មានថ្មីៗ រួមទាំងកញ្ចប់បន្តឡើងវិញផងដែរ។ សកម្មភាពនេះនឹងធ្វើឱ្យប្រាកដថា តំបន់មានព័ត៌មានថ្មីបំផុតដែលខ្លួនត្រូវការ ដើម្បីបន្តការធានារ៉ាប់រង Medi-Cal របស់អ្នកឡើងវិញ។ វាក៏នឹងជួយឱ្យតំបន់ដឹងថាតើអ្នកមានលក្ខណសម្បត្តិក្នុងការទទួលបានការធានារ៉ាប់រងដែលមានតម្លៃទាប ឬឥតគិតថ្លៃផងដែរ។ |
| តើខ្ញុំនឹងត្រូវបានផ្តាច់ពីការធានារ៉ាប់រង Medi-Cal ដែរទេ ប្រសិនបើខ្ញុំបានទទួលប្រាក់រំអែងគ្គាស អំឡុងពេល | **តំបន់/គម្រោងថែទាំដែលស្ថិតក្រោមការគ្រប់គ្រង/ការឆ្លើយតបរបស់ដៃគូសហគមន៍៖** សូមរាយការណ៍អំពីការផ្លាស់ប្តូរប្រាក់ចំណូលទៅការិយាល័យក្នុងតំបន់របស់អ្នក។ ប្រសិនបើប្រាក់ចំណូល |

| | |
|---|---|
| មានអាសន្ននៃសុខភាពសាធារណៈ ដោយសារ COVID-19 ? | របស់អ្នកកើនឡើង ឬគ្រួសាររបស់អ្នកមានការផ្លាស់ប្តូរ ដរាបណាភាពមានអាសន្ននៃសុខភាពសាធារណៈដោយសារ COVID-19 បន្ត អ្នកនឹងមិនបាត់បង់ការធានារ៉ាប់រង Medi-Cal របស់អ្នកឡើយ។ |
| ខ្ញុំបានផ្លាស់ទី។ តើខ្ញុំគួរប្រាប់នរណាថាខ្ញុំបានផ្លាស់ទី ? | **ការឆ្លើយតបរបស់តំបន់៖** យើងអាចធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នក។ អ្នកអាចរាយការណ៍អំពីការផ្លាស់ប្តូរនេះតាមទូរសព្ទ តាមអ៊ីនធឺណិត សំបុត្រ ទូរសារ ឬដោយផ្ទាល់។<br><br>**ការឆ្លើយតបរបស់គម្រោងថែទាំដែលស្ថិតក្រោមការគ្រប់គ្រង៖** យើងអាចធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នកសម្រាប់គម្រោងថែទាំដែលស្ថិតក្រោមការគ្រប់គ្រង។ វាជារឿងសំខាន់ដែលយើងចែករំលែកព័ត៌មាននេះជាមួយតំបន់ដើម្បីឱ្យអ្នកអាចបន្តទទួលបានសេចក្តីជូនដំណឹងសំខាន់ៗអំពី Medi-Cal របស់អ្នក។ តើវាគ្មានបញ្ហាសម្រាប់អ្នកទេមែនទេ ? ប្រសិនបើអ្នកមិនចង់ឱ្យយើងចែករំលែកអាសយដ្ឋានថ្មីរបស់អ្នកជាមួយការិយាល័យក្នុងតំបន់របស់អ្នកទេ អ្នកនឹងត្រូវទាក់ទងការិយាល័យនោះដោយផ្ទាល់ ហើយផ្តល់ព័ត៌មានថ្មីរបស់អ្នក។ [បញ្ចូលព័ត៌មានទំនាក់ទំនងក្នុងតំបន់]<br><br>**ការឆ្លើយតបរបស់ដៃគូសហគមន៍៖** សូមទាក់ទងការិយាល័យក្នុងតំបន់របស់អ្នក ដើម្បីផ្តល់អាសយដ្ឋានថ្មីរបស់អ្នក ដើម្បីធានាថាការធានារ៉ាប់រង Medi-Cal របស់អ្នកបន្ត។ [បញ្ចូលព័ត៌មានទំនាក់ទំនងក្នុងតំបន់] |

| [ស្គ្រីបហៅទូរសព្ទ IVR] |
|---|
| ប្រសិនបើអ្នកបានផ្លាស់ទីក្នុងរយៈពេលពីរឆ្នាំចុងក្រោយ សូមផ្តល់អាសយដ្ឋានថ្មីរបស់អ្នកទៅការិយាល័យ Medi-Cal ក្នុងតំបន់របស់អ្នក ដើម្បីធានាថាអ្នកបន្តទទួលបានព័ត៌មានសំខាន់ៗអំពីការធានារ៉ាប់រង Medi-Cal របស់អ្នក។ |
| ប្រសិនបើអ្នកមានការផ្លាស់ប្តូរក្នុងគ្រួសាររបស់អ្នកដូចជា ប្រាក់ចំណូល នរណាម្នាក់មានផ្ទៃពោះ សមាជិកគ្រួសារថ្មី ឬអាសយដ្ឋាន សូមរាយការណ៍អំពីការផ្លាស់ប្តូរទាំងនោះទៅការិយាល័យ Medi-Cal ក្នុងតំបន់របស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើបាន។ |
| ប្រសិនបើព័ត៌មានទំនាក់ទំនងរបស់អ្នក (លេខទូរសព្ទ អ៊ីមែល អាសយដ្ឋានផ្ញើសំបុត្រ) បានផ្លាស់ប្តូរ សូមរាយការណ៍អំពីការផ្លាស់ប្តូរទាំងឡាយទៅការិយាល័យ Medi-Cal នៅក្នុងតំបន់របស់អ្នកតាមអ៊ីនធឺណិត ឬតាមទូរសព្ទ អ៊ីមែល ទូរសារ ឬដោយផ្ទាល់។ |